ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២៦១/១៣-ប្រាយសិន អ៊ិនធើណេសិនណល ខបភើរេសិន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **កៅ ថាច**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ប្រាយសិន អ៊ិនធើណេសិនណល ខបភើរេសិន**

អាសយដ្ឋាន ៖ ភូមិឧកញ្ញាទេព ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០១១ ៨៨ ៩៩ ៦៧ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

- កញ្ញា កែ ឆដាផស្ស មេធាវីតំណាងក្រុមហ៊ុន

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា**

- **សហជីពសាមគ្គីភាពការងារកម្ពុជាប្រចាំក្រុមហ៊ុន ប្រាយសិន អ៊ិនធើណេសិនណល ខបភើរេសិន**

អាសយដ្ឋាន ៖ ផ្ទះលេខ១៧E ផ្លូវ២០០៤ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៧២ ៨៤ ៧២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោក សៀង វិទ្ធី ប្រធានសហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥ ២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ◆ Website: www.arbitrationcouncil.org

២- លោក បៃ បូរ៉ា អគ្គលេខាធិការរងសហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា

៣- លោក ឆន សុខគា មន្ត្រីសហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា

៤- កញ្ញា ឡេង ចាន់ដារ៉ា ប្រធានស្តីទីសហជីពសាមគ្គីភាពការងារកម្ពុជាប្រចាំក្រុមហ៊ុន ប្រាយសិន អ៊ិនធើនេសិនណល ខបភើរេសិន

៥- អ្នកស្រី សួន គីមសួ លេខាសហជីពសាមគ្គីភាពការងារកម្ពុជាប្រចាំក្រុមហ៊ុន ប្រាយសិន អ៊ិនធើនេសិនណល ខបភើរេសិន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ភាគីសហជីពមិនព្រមឱ្យក្រុមហ៊ុនធ្វើការបោះឆ្នោតជ្រើសរើសតំណាងកម្មករនោះទេ ដោយតម្រូវឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យថ្នាក់ដឹកនាំរបស់ខ្លួនពីររូបឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតទើបអាចបោះឆ្នោតបាន។ ចំណែកភាគីក្រុមហ៊ុនវិញមិនអាចអនុញ្ញាតឱ្យថ្នាក់ដឹកនាំសហជីពទាំងពីររូបនោះឈរឈ្មោះបាននោះទេ ដោយលើកហេតុផលថា អ្នកទាំងពីរនេះមិនទាន់មានអតីតភាពការងារគ្រប់ ៦ ខែនៅឡើយ និងមិនអាចអានសរសេរភាសាខ្មែរបាន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួម លេខ ១៦០៤/១៣ របក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ ព្រឹក )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ បានទទួលបណ្តឹង

THE ARBITRATION COUNCIL

មួយច្បាប់របស់សហព័ន្ធសាមគ្គីភាពការងារកម្ពុជា ស្តីពីការជំទាស់មិនឱ្យក្រុមហ៊ុនធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំរោងចក្រ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣។ ក្រោយពីបានទទួលពាក្យបណ្តឹងរួច លោកប្រធានមន្ទីរការងារខេត្តបានចាត់តាំងឱ្យអ្នកផ្សះផ្សាធ្វើការអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មាន និងធ្វើការផ្សះផ្សាឱ្យបានមុនថ្ងៃ ដែលក្រុមហ៊ុនជូនដំណឹងបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំរោងចក្រ។ នៅព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ អ្នកផ្សះផ្សាបានទៅសាកសួរព័ត៌មានភាគីនិយោជកដល់ក្រុមហ៊ុនផ្ទាល់ និងបានអញ្ជើញភាគីសហជីពមកផ្តល់ព័ត៌មាននៅមន្ទីរការងារខេត្តនៅពេលរសៀលថ្ងៃដដែល។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ អ្នកផ្សះផ្សាបានអញ្ជើញភាគីទាំងពីរ មកធ្វើការសម្របសម្រួលគ្នានៅមន្ទីរការងារខេត្ត។ ក្នុងពេលផ្សះផ្សា ភាគីសហជីពមិនព្រមឱ្យក្រុមហ៊ុនធ្វើការបោះឆ្នោតជ្រើសរើសតំណាងកម្មករនិយោជិតនោះទេ ដោយតម្រូវឱ្យក្រុមហ៊ុនអនុញ្ញាតិឱ្យថ្នាក់ដឹកនាំរបស់ខ្លួនពីររូបឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតទើបអាចបោះឆ្នោតបាន។ ចំណែកឯភាគីក្រុមហ៊ុនវិញមិនអនុញ្ញាតឱ្យថ្នាក់ដឹកនាំសហជីពទាំងពីររូបនោះឈរឈ្មោះបោះឆ្នោតបាននោះទេ ដោយលើកហេតុផលថា អ្នកទាំងពីរនេះមិនទាន់មានអតីតភាពការងារគ្រប់ ០៦ ខែនៅឡើយ និងមិនអាចអាន សរសេរ ភាសាខ្មែរបាន។ ដោយមិនអាចចរចាគ្នាបាន ភាគីទាំងពីរសំណូមពរឱ្យអ្នកផ្សះផ្សាបញ្ជូនសំណុំរឿងនេះទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ១៦០៤/១៣ របក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ វេលាម៉ោង ០៨៖៣០ នាទីព្រឹក។ ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០១ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣ ជាថ្ងៃផុតកំណត់នៃការដាក់ភស្តុតាង និងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ ជាថ្ងៃផុតកំណត់នៃការជំទាស់ភស្តុតាង។ ភាគីទាំងពីរបានឯកភាពពន្យារពេលចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ ទៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៣។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីផលប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះជាសេចក្តីសម្រេច ដែលជាប-

THE ARBITRATION COUNCIL

កាតព្វកិច្ច តាមរយៈអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ រួចហើយ។ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍។ យោងតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនេះ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីផលប្រយោជន៍ នឹងមិនបណ្តាលឱ្យប៉ះពាល់ដល់កាតព្វកិច្ច ក្នុងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីសិទ្ធិទេ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសយកប្រភេទសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច ចំពោះវិវាទអំពីផលប្រយោជន៍។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទដែលនៅសល់ខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រុមហ៊ុន ប្រាយ សិន អ៊ិនធើណេសិនណល ខបភើរេសិន ប្រគល់សិទ្ធិជូនមេធាវី កែ ឆដាផស្ស ជាមេធាវីតំណាងដោយអាណត្តិរបស់ក្រុមហ៊ុននៅចំពោះមុខអាជ្ញាកណ្តាល រៀបចំតាក់តែងឯកសារដើម្បីឆ្លើយតបទៅនឹងការទាមទាររបស់កម្មករ និងមានសិទ្ធិឆ្លើយតប ឬតវ៉ានិងការសម្រេចផ្សេងៗ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុន។

២- ពាក្យសុំជូនពិនិត្យភស្តុតាង របស់មេធាវី កែ ឆដាផស្ស គោរពជូនប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសុំជូនភស្តុតាងរបស់ក្រុមហ៊ុន ប្រាយសិន អ៊ីនធើណេសិណល ខបភើរេសិន លេខ ១៤១/ឆសប/១៣ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣។

៣- លិខិតលេខ ៤០៣/១៣ សសកពក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គោរពជូន លោកនាយកក្រុមហ៊ុន ប្រាយសិន អ៊ិនធើណេសិនណល់ ស្តីពីការជូនដំណឹងមេដឹកនាំជាប់ឆ្នោតសហជីពសេរីកម្មករនៃក្រុមហ៊ុន ប្រាយសិន អ៊ិនធើណេសិនណល់។

៤- ឯកសារពាក់ព័ន្ធឈ្មោះ ស្រេង ឈុនឡុង។

៥- ឯកសារពាក់ព័ន្ធឈ្មោះ គង់ សុខគៀង។

៦- ឯកសារពាក់ព័ន្ធឈ្មោះ ផន សុផាត។

៧- លិខិតអំពាវនាវរបស់សមាគមកម្មករ។

ARBITRATION COUNCIL

៨- លិខិតស្នើសុំរបស់សហព័ន្ធសមាគមកម្មករក្នុងក្រុមហ៊ុន ប្រាយសិន និងបញ្ជីឈ្មោះ ស្នាមមេដៃសមាជិកចូលរួមក្នុងសមាគមកម្មករ។

៩- លិខិតជូនដំណឹងរបស់ក្រុមហ៊ុន ប្រាយសិន អ៊ិនធើណេសិនណល់ ខបភើរេសិន ស្តីពីជូនដំណឹងដល់កម្មករទាំងពីរភេទមានបំណងធ្វើជាតំណាងកម្មករក្នុងក្រុមហ៊ុន ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣។

១០- សន្លឹកឆ្នោតសម្រាប់បេក្ខជនបេក្ខនារី ឈរឈ្មោះដើម្បីធ្វើជាតំណាងប្រតិភូពេញសិទ្ធ និងជំនួយ។

១១- កិច្ចសន្យាស្តីពីការហ្វឹកហ្វឺនកូនជាង របស់ឈ្មោះ ផន សុផាត, ឡេង សុខលីម, យ៉ែម នៅ, រីន ចាន់រី, នុត តាវ, ចេវ វន និង ឃិន បូរី។

១២- បញ្ជីឈ្មោះកម្មករចូលថ្មី និងតារាងពិនិត្យបញ្ជាក់ទទួលយកធ្វើការ អត្តសញ្ញាណប័ណ្ណ របស់ឈ្មោះ ស្រេង ឈុនឡេង, គង់ សុខគៀង

ខ- ឯកសារបានទទួលពីភាគីនិយោជិត ៖

១- លិខិតលេខ ៣៨៩ កប របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣ បញ្ជាក់ថា សហជីពសាមគ្គីភាពការងារកម្ពុជាប្រចាំក្រុមហ៊ុន ប្រាយសិន អ៊ីនធើណេសិនណល ខបភើរេសិន ត្រូវបានចុះបញ្ជិការនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកានេះតទៅ។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពសាមគ្គីភាពការងារកម្ពុជាប្រចាំក្រុមហ៊ុន ប្រាយសិន អ៊ីនធើណេសិនណល ខបភើរេសិន ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣។

៣- លក្ខន្តិកៈសហជីពសាមគ្គីភាពការងារកម្ពុជាប្រចាំក្រុមហ៊ុន ប្រាយសិន អ៊ីនធើណេសិនណល ខបភើរេសិន បានចុះបញ្ជីកាលេខ ៣០៨៥ កប/វក នៅនាយកដ្ឋានវិវាទការងារ ភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១៣។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ប្រាយ សិន អ៊ិនធើណេសិនណល លេខ ១៦០៤/១៣ របក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ប្រាយ សិន ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៣០១ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៣០២ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣។

THE ARBITRATION COUNCIL

៣- កិច្ចព្រមព្រៀងលើសេចក្តីបង្គាប់ជាប់កាត្តកិច្ចចំពោះចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១៣។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុ ប្រាយសិន អ៊ិនធើនេសិនណល ខបភើរេសិន (តទៅនេះហៅថា "ក្រុមហ៊ុន ប្រាយសិន") ជាក្រុមហ៊ុនផលិតស្បែកជើង *(យោងតាមកំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន ប្រាយសិន អ៊ិនធើនេសិនណល ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣)*។ ក្រុមហ៊ុននេះជួលកម្មករនិយោជិត សរុបប្រមាណជា ១០៥៧ នាក់ *(តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ១៦០៤/១៣ របក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣)*។
- សហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា គឺជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពសាមគ្គីភាពការងារកម្ពុជាទទួលបានបញ្ជិកាសហជីពលេខ ៣០៨៥ កប/វក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១៣ ដែលមានកម្មករ ផេង ការ៉េន, កម្មការិនី ឡេង ចាន់ដារ៉ា និង កម្មការិនី សួន គឹមសួ ជាប្រធាន, អនុប្រធាន និងលេខាធិការិនីសហជីព។

**ចំណុចវិវាទ ៖ *ភាគីកម្មករនិយោជិតទាមទារថា ឱ្យនិយោជកអនុញ្ញាតិឱ្យថ្នាក់ដឹកនាំរបស់ខ្លួនពីររូបឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតទើបអាចបោះឆ្នោតបាន***

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកទទួលថ្នាក់ដឹកនាំសហជីពសាមគ្គីភាពការងារកម្ពុជាចំនួន ០២ នាក់ គឺកម្មការិនី ឡេង ចាន់ដារ៉ា និងកម្មការិនី សួន គឹមសួ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ប្រាយសិន។
- និយោជកបានបិតប្រកាសជូនដំណឹងដល់កម្មករនិយោជិត អំពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក និងបានប្រកាសឱ្យកម្មករនិយោជិតអាចឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក។
- សហជីពសាមគ្គីភាពការងារកម្ពុជា បានដាក់ឈ្មោះកម្មការិនី ឡេង ចាន់ដារ៉ា និងកម្មការិនី សួន គឹមសួ ជាបេក្ខជនបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកនេះ។
- និយោជកមិនអនុញ្ញាតិឱ្យកម្មការិនីទាំង ០២ នាក់ឈរឈ្មោះជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកទេ ដោយមូលហេតុថា ពួកគាត់ទាំង ០២ នាក់ ចេះអានភាសាខ្មែរបានតិចតួច និងមិនចេះសរសេរអក្សរខ្មែរទេ។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេច ៖**

មុននឹងពិចារណាចំណុចទាមទាររបស់ភាគីកម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការបកស្រាយអំពីវិវាទអំពីសិទ្ធិ ឬវិវាទអំពីផលប្រយោជន៍ជាមុនសិន។

មាត្រា ៣១២ កថាខ័ណ្ឌទី២ នៃច្បាប់ស្តីពីការងារ ចែងថា *"ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ ចំពោះការវិវាទដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តន៍បញ្ញត្តិច្បាប់ ឬអនុសញ្ញារួមណាមួយ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់"*។

ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ចែងថា *"សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលដោះស្រាយវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍នឹងមកជំនួសអនុសញ្ញារួមសម្រាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសេចក្តីបង្គាប់នោះចូលជាស្ថាពរ លើកលែងតែភាគីចរចាបង្កើតអនុសញ្ញារួមមួយ ដើម្បីជំនួសសេចក្តីបង្គាប់នេះ"*។

យោងតាមមាត្រា ៣១២ កថាខ័ណ្ឌទី២ នៃច្បាប់ស្តីពីការងារ និងប្រការ ៤៣ នៃប្រកាសលេខ ០៩៩ បានបញ្ជាក់ពីការដោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោយផ្អែកលើច្បាប់ អនុសញ្ញារួម និងបទដ្ឋានដែលពាក់ព័ន្ធផ្សេងៗទៀត។ ចំពោះវិវាទក្រៅពីនេះ គឺអាជ្ញាកណ្តាលត្រូវដោះស្រាយដោយសមធម៌ ដែលវិវាទនោះ គឺជាវិវាទអំពីផលប្រយោជន៍។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិ ដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង អនុសញ្ញារួម បទបញ្ជាផ្ទៃក្នុង ឬការអនុវត្តកន្លងមកណាមួយចែងអំពីការទាមទារនោះ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទអំពីសិទ្ធិតាមផ្លូវច្បាប់។ រីឯវិវាទអំពីផលប្រយោជន៍ គឺជាវិវាទដែលមិនមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង អនុសញ្ញារួម បទបញ្ជាផ្ទៃក្នុង ឬការអនុវត្តកន្លងមកណាមួយ ចែងអំពីការទាមទារនោះ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទអំពីផលប្រយោជន៍តាមផ្លូវសមធម៌។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលថ្នាក់ដឹកនាំសហជីពសាមគ្គីភាពការងារកម្ពុជា ចំនួន ០២ នាក់ គឺកម្មការិនី ឡេង ចាន់ដារ៉ា និងកម្មការិនី សួន គឹមសួ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ប្រាយសិន**

ជាបឋម ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើចំណុចវិវាទនេះ ជាវិវាទអំពីសិទ្ធិ ឬវិវាទអំពីផលប្រយោជន៍?

ដោយសារការទាមទារនៅក្នុងចំណុចនេះ ទាក់ទងនឹងសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ដែលមានចែងនៅក្នុងច្បាប់ស្តីពីការងារ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះ គឺជាវិវាទអំពីសិទ្ធិ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតបានទាមទារ ឱ្យនិយោជកទទួលថ្នាក់ដឹកនាំសហជីពសាមគ្គីភាពការងារកម្ពុជា ចំនួន ០២ នាក់ គឺកម្មការិនី ឡេង ចាន់ដារ៉ា និងកម្មការិនី សួន គឹមសួ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ប្រាយសិន។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការ ក្នុងការសម្រេចសេចក្តីលើចំណុចវិវាទនេះដែរ ឬទេ?

THE ARBITRATION COUNCIL

មាត្រា ២៩៨ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា ៖ *"ការតវ៉ាផ្សេងៗទាក់ទងនឹងការបោះឆ្នោត សិទ្ធិឈរឈ្មោះ ភាពខុសត្រូវនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកត្រូវដាក់ជូនតុលាការការងារ ឬបើមិនទាន់មានតុលាការការងារទេ ត្រូវដាក់ជូនតុលាការអាជ្ញាកតិដែលមានសមត្ថកិច្ចសំរេចសេចក្តីជាបន្ទាន់ និងជាចុងក្រោយ ។"*

តាមរយៈមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រាល់វិវាទដែលទាក់ទងការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក សិទ្ធិឈរឈ្មោះជ្រើសរើសជាប្រតិភូបុគ្គលិក ភាពខុសត្រូវនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ត្រូវដាក់ជូនទៅតុលាការការងារ ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការសម្រេចសេចក្តីលើបញ្ហាវិវាទនេះ ជាបន្ទាន់ និងជាចុងក្រោយ ។ ក្នុងករណីមិនទាន់មានតុលាការការងារ សមត្ថកិច្ចក្នុងការសម្រេចសេចក្តីនេះ ត្រូវប្រគល់ជូនតុលាការអាជ្ញាកតិ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការក្នុងការសម្រេចសេចក្តីរាល់បញ្ហាវិវាទ ដែលមានចែងក្នុងមាត្រា ២៩៨ នៃច្បាប់ស្តីពីការងារនេះទេ ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលថ្នាក់ដឹកនាំសហជីពសាមគ្គីភាពការងារកម្ពុជា ចំនួន ០២ នាក់ គឺកម្មការិនី ឡេង ចាន់ដារ៉ា និងកម្មការិនី សួន គីមសួ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ប្រាយសិន ។ ពោលគឺ បញ្ហាវិវាទនៅក្នុងសំណុំរឿងនេះ គឺជាវិវាទទាក់ទងនឹងសិទ្ធិឈរឈ្មោះជ្រើសរើសជាប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ប្រាយសិន ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការក្នុងការសម្រេចសេចក្តីលើវិវាទនេះទេ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកទទួលថ្នាក់ដឹកនាំសហជីពសាមគ្គីភាពការងារកម្ពុជា ចំនួន ០២ នាក់ គឺកម្មការិនី ឡេង ចាន់ដារ៉ា និងកម្មការិនី សួន គីមសួ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ប្រាយសិន ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ÷**

**ចំណុចវិវាទ ៖**

បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកទទួលថ្នាក់ដឹកនាំសហជីពសាមគ្គីភាពការងារកម្ពុជា ចំនួន ០២ នាក់ គឺកម្មការិនី ឡេង ចាន់ដារ៉ា និង កម្មការិនី សួន គីមសួ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ប្រាយសិន ។

**ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖**

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០១២ ។*

THE ARBITRATION COUNCIL

**២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ÷ គ្មាន**

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **កៅ ថាច**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL